ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០១៣

នៅក្នុងខែមីនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបំពេញការងារពាក់ព័ន្ធនឹងមូលដ្ឋានរបស់ថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា ដើម្បីលើកកម្ពស់មុខងារតំណាង និងមុខងារត្រួតពិនិត្យ បន្តការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កសាងគោលនយោបាយសង្គមកិច្ច ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងបានបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម។

## ១.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបប្រជុំពិភាក្សាជាមួយឯកឧត្តម លោកជំទាវ ជាប្រធានគណៈកម្មការ និងជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត Ounkeo Vouthilath ប្រធានខុទ្ទកាល័យរដ្ឋសភា នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលរួមក្នុងពិធីជំនួបសវនាការរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូន-ទទួលដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារក្នុង/ក្រៅប្រទេស ចូលរួមមហាសន្និបាតលើកទី១២៨ របស់សហភាពអន្តរសភា IPU នៅទីក្រុង Quito សាធារណរដ្ឋអេក្វាឌ័រ បន្តជម្រុញការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ អន្តរជាតិ ប្រជុំពិភាក្សាការងារ និងបានពិនិត្យសម្រេចលើឯកសារផ្សេងៗចំនួន៥១០ច្បាប់។

-រៀបចំពិធីជូន **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រមុខរដ្ឋស្តីទីទទួលសារតាំងពីឯកឧត្តម Merge MOSTURA ឯកអគ្គរដ្ឋទូតតែងតាំងថ្មីនៃសាធារណរដ្ឋបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

-បានរៀបចំពិធីជំនួបសម្តែងការគួរសមរវាងឯកឧត្តម **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា ជាមួយគណៈប្រតិភូនារីដឹកនាំដោយលោកជំទាវ អ៊ឹង កន្ថាផាវី ក្នុងឱកាសខួបលើកទី១០២ ទិវានារីអន្តរជាតិ ៨មីនា ឆ្នាំ២០១៣ ។

-បានរៀបចំបែបបទជូន ទទួល អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះបំពេញ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

បេសកកម្ម ជួបសវនាការជាមួយក្រសួងនានា ទស្សនកិច្ច ចូលរួមមហាសន្និបាត កិច្ចប្រជុំនានា ទាំងក្នុង និងក្រៅប្រទេស ចំនួន០៧លើក ។

-បានទទួលសេចក្តីព្រាងច្បាប់ពីរដ្ឋាភិបាលចំនួន០១ច្បាប់ បានចម្លងចែកជូនគ្រប់សមាជិក សមាជិកា ព្រឹទ្ធសភា ។

-បានចុះបំពេញការងារជាមួយលោកជំទាវ មាន សំអាន ប្រធានក្រុមមិត្តភាពកម្ពុជា-វៀតណាម ចុះត្រួតពិនិត្យទីតាំង និងពិភាក្សាការងារជាមួយឯកឧត្តមប្រធានមន្ទីរពេទ្យកាល់ម៉ែតត្រៀមរៀបចំ ពិនិត្យ ព្យាបាល វះកាត់ភ្នែក ព្រមទាំងចែកអំណោយជូនបងប្អូនប្រជាពលរដ្ឋ ។

-បានចុះបំពេញការងារជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តវៀតណាម និងសប្បុរសជនវៀតណាម ចុះចែកអំណោយ និងពិនិត្យជំងឺដល់ប្រជាពលរដ្ឋនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំចំនួន ៨០០នាក់។

-រៀបចំឯកសារលទ្ធកម្ម នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើកម្មវិធីចំណាយសម្រាប់ត្រីមាស ទី២ ឆ្នាំ២០១៣ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកគម្រោងស្នើសុំសម្ភារៈជូនគ្រប់អង្គភាពចំនួន២៩ សំណើ ថតចម្លងឯកសារចំនួន១៤៩សំណើ និងចងក្រងឯកសារជាសៀវភៅចំនួន៤១ក្បាល ដោះស្រាយសម្ភារ និងសំណើថវិកាចំនួន១៤៤សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន១៤៨លើក។

-បានប្រគល់ម៉ាស៊ីនត្រជាក់ចំនួន០៥គ្រឿង និងស្លាកលេខរថយន្តចំនួន០២គ្រឿង។ តម្លើង បញ្ចូលហ្គាស ជួសជុល ទូរទស្សន៍ ព្រីនធ័រ ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនថតចម្លង ទូទឹកកក ទូរស័ព្ទ កៅអីវិលធំ សោត ឌីសង់ទ័រ បន្ទប់ទឹក ប្តូរអំពូល ព្រី កុងតាក់ ចំនួន២០៣គ្រឿង។

-បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៥វគ្គ បានទំនាក់ទំនងទៅសាលា CWF សុំបាន មន្ត្រី០៣នាក់ទៅរៀនភាសាអង់គ្លេសវគ្គបន្ត ក្រសួងការបរទេស និងស្ថានទូត India, Brunei, Singapore និងPhilippine ស្តីពីការសុំអាហារូបករណ៍សម្រាប់មន្ត្រី ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ច ប្រជុំ និងពិធីផ្សេងៗ ចំនួន២១លើក។

-បានធ្វើ និងផ្សព្វផ្សាយរបាយការណ៍ និងសម្រង់ស្ថិតិស្តីពីលទ្ធផលការងាររបស់អគ្គលេខាធិការ ដ្ឋានព្រឹទ្ធសភា និងព្រឹទ្ធសភា ចំនួន២៦០ច្បាប់។

-យកព័ត៌មាន និងថតសកម្មភាពការងាររបស់ព្រឹទ្ធសភា និងពិធីផ្សេងៗសរុបចំនួន៥៣លើក ផ្សព្វផ្សាយ ខ្សែVideo ស្តីពីសមិទ្ធផលព្រឹទ្ធសភា ០១ឆ្នាំ នីតិកាលទី៣ព្រឹទ្ធសភា ព្រមទាំងធ្វើព្រឹត្តិបត្រ

ព័ត៌មានប្រចាំថ្ងៃ (ព័ត៌មានជាតិ តំបន់ និងអន្តរជាតិ) ចំនួន ៧៥៥អត្ថបទ។

-ជួសជុលកុំព្យូទ័រ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office និងចុះតាមដាន Internet និង Network សរុប ចំនួន៤៤គ្រឿង ។ ស្រាវជ្រាវកម្មវិធីចងក្រងគន្ថីះកុំព្យូទ័រចំនួន០៣កម្មវិធី។ បានUpload ព័ត៌មាន និងឯកសារផ្សេងៗចំនួន២៤ប្រធានបទ និងបង្ហោះក្នុងវិបសាយ ចំនួន២៥ប្រធានបទ។

-ទទួលអ្នកចូលអានសៀវភៅនៅក្នុងបណ្ណាល័យ ចំនួន៣៣០នាក់ និងបានទទួលឯកសារ សៀវភៅ ព្រឹត្តិបត្រ កាសែត និងទស្សនាវដ្តី ចំនួន១២៨ច្បាប់ និង១៥៤ក្បាល ។ បោះត្រាសៀវភៅ និងបិទប័ណ្ណខ្ចី-សងលើសៀវភៅ ចំនួន២៩៤ក្បាល បញ្ចូលសៀវភៅជាភាសាអង់គ្លេសក្នុងកម្មវិធីបណ្ណាល័យខ្ញុំ ចំនួន២៥០ក្បាល ចូលក្នុងបញ្ជីចំនួន១៥៤ក្បាល ដាក់គ្រប ផ្លាស់ប្តូរ និងដាក់លេខកូដសៀវភៅ ចំនួន១៩៤ក្បាល និងបញ្ជូនសៀវភៅទៅសេវាអ្នកអាន ចំនួន១៥៦ក្បាល។

-បានទទួលលិខិតចូល និងព្រឹត្តិបត្រព័ត៌មានពីក្រៅស្ថាប័ន ចំនួន ៧៧១ច្បាប់ ព្រមទាំងបានបញ្ជូនឯកសារផ្សេងៗទៅក្រៅស្ថាប័ន និងផ្ទៃក្នុងព្រឹទ្ធសភា ចំនួន ១.៧៤២ច្បាប់ ។ បានទទួលពាក្យបណ្តឹង និងធ្វើកំណត់បង្ហាញជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន ០៣ករណី។

-តាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុង ត្រួតពិនិត្យការអនុវត្តផែនការការងារប្រចាំខែនីមួយៗនៅគ្រប់អង្គភាព និងបានត្រួតពិនិត្យប័ណ្ណចំណូល-ចំណាយទូទៅរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

**២.ទិសដៅការងារខែមេសា ឆ្នាំ២០១៣**

១-ត្រៀមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំវិសាមញ្ញលើសេចក្តីព្រាងច្បាប់ស្តីពីការបង្ការ និងការពន្ធត់អគ្គិភ័យ និងសេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្ម។

២-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអគ្គទូតនានា។

៣-ត្រៀមជួយសម្រួលការជួបសំនេះការរវាងគណៈកម្មការ និងក្រសួងនានា និងការចុះបេសកកម្មតាមបណ្តាខេត្ត។

-ថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងចែកអំណោយដល់នគរបាលការពារព្រំដែននៅព្រំដែនកម្ពុជា-ឡាវ និងចុះសួរសុខទុក្ខកងយោធពលខេមរភូមិន្ទ នៅកោះពូឡូវៃ។

៤-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញទស្សនកិច្ចក្រៅប្រទេស។

៥-ត្រៀមចូលរួមរៀបចំសិក្ខាសាលា និងវេទិកាក្នុង/ក្រៅព្រឹទ្ធសភា ព្រមទាំងក្នុង/ក្រៅប្រទេស។

៦-ត្រៀមធ្វើរបាយការណ៍ចន្លោះសម័យប្រជុំ និងបន្តកែសម្រួលទម្រង់ របាយការណ៍ឲ្យមានលក្ខណៈជាស្តង់ដារួម ។

៧-បន្តជម្រុញការសាងសង់អគារ០៣ខ្នង ជំរុញភាគីចិននូវសំណើជំនួយ សុំបន្ថែមពីរដ្ឋាភិបាលចិន,កសាងបែបបទ/នីតិវិធីដេញថ្លៃជណ្តើរយន្ត និងដំណើរការសិក្សាប្លង់គោល៤វិស័យ ( ប្រព័ន្ធលូ, ប្រព័ន្ធផ្លូវថ្នល់, ប្រព័ន្ធថាមពលព្រះអាទិត្យ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន) ការសិក្សាប្លង់មេ (ភាពយូរអង្វែងនៃការទទួលជំនួយ) បែបបទជំនួយពីរដ្ឋសភាវៀតណាម និងសាកលវិទ្យាល័យធុរកិច្ច និងបច្ចេកវិទ្យាល័យហាណូយ ជំនួយសំភារៈ បរិក្ខា ជំហានទី២ ទី៣ ពីក្រុមហ៊ុនម៉ាឡេស៊ី ។

៨-ចាប់ផ្តើមដំណើរការអង្គភាពថវិការបស់អគ្គនាយកដ្ឋានទាំងបី អគ្គាធិការដ្ឋាន និងខុទ្ទកាល័យអគ្គលេខាធិការរង ។

៩-បញ្ចប់នីតិវិធីលទ្ធកម្ម និងត្រៀមកាត់ឯកសណ្ឋានជូនមន្ត្រីរាជការសម្រាប់ឆ្នាំ២០១៣ ។

១០-ត្រៀមបើកប្រាក់ឧបត្ថម្ភ ពិធីសូត្រមន្តរាប់បាត រៀបចំពិធីជប់លៀង ល្បែងកំសាន្តតាមប្រពៃណី របាំត្រុដិ និងពិធីផ្សេងៗទៀតក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ។

**៣.សេចក្តីសន្និដ្ឋាន**

ក្នុងខែមីនានេះ ជារយៈពេលវិស្សមកាលរបស់ព្រឹទ្ធសភា ជារួមអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបំពេញការងារជាច្រើនជូនថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា ចុះបំពេញការងារមូលដ្ឋានដើម្បីលើកកម្ពស់មុខងារតំណាង មុខងារត្រួតពិនិត្យ ។ ដោយឡែកការងាររដ្ឋបាល ហិរញ្ញវត្ថុ ការងារបណ្តុះបណ្តាល និងសេវាផ្សេងៗទៀតសម្រេចបានលទ្ធផលល្អប្រសើរ ។៚

ភ្នំពេញ, ថ្ងៃទី[illegible]ខែមីនា ឆ្នាំ២០១៣

**អគ្គលេខាធិការស្តីទី**

ឡោក_ឆាយ